គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

CFC-CBC 07082020KH

# <u>សេចក្តីថ្លែងការណ៍</u>

## ផែនទី បង្គោលព្រំដែន នៃ អាណានិគមនិយមយួន

ផែនទីបង្គោលព្រំដែន ឬផែនទីឋានលេខាព្រំដែនគោក ដែលគេប្រកាស កាលពីថ្ងៃទី១ សីហា ២០២០ នេះ ជាផែនទីនៃការរំលោភដាក់ស្តែងមួយទៀត នៃយៀកណាម មកលើឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី នៃប្រទេសកម្ពុជាជាប្រាកដ។

នៅក្នុងសេចក្តីប្រកាសព័ត៌មាននៃរដ្ឋាភិបាល ហ៊ុន សែន (ថ្ងៃ០៤/០៨/២០២០) គេថា «ខ្សែព្រំដែន ដែលមាននៅលើ**ផែនទីឋានលេខាព្រំដែន ខ្នាត១/២៥.០០០ ត្រឹមត្រូវតាមខ្សែព្រំដែន ដូចមាននៅលើផែនទី បោន ខ្នាត ១/១០០.០០០ បោះពុម្ពដោយ ក្រុមភូមិសាស្ត្រឥណ្ឌូចិន** ស្របតាមមាត្រា២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា...»។ រីឯនៅក្នុងសេចក្តីប្រកាសព័ត៌មាន នៃទីក្រុងហាណូយវិញ (ថ្ងៃ០១/០៨/២០២០) គេគ្មាននិយាយ**អំពី**ផែនទី បោន ខ្នាត ១/១០០.០០០ ហ្នឹងទេ ប៉ុន្តែគេអះអាងថា ជាផែនទីនៃការកំណត់ព្រំដែន និងការបោះបង្គោលព្រំដែនគោក យៀកណាម-កម្ពុជា ដោយយោងតាមសន្ធិសញ្ញាព្រំដែនជាតិ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥ លើសន្ធិសញ្ញា ឆ្នាំ១៩៨៥ នោះ(https://fr.vietnamplus.vn/ceremonie-de-reception-de-la-carte-topographique-de-la-frontiere-vietnamcambodge/142771.vnp)។

យើងត្រូវរំលឹកជាថ្មីដែរ អំពីលក្ខណៈច្បាប់ និងទិន្នន័យបច្ចេកទេសនៃសន្ធិសញ្ញាឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥ របស់យួននោះ ៖

**១-** សន្ធិសញ្ញាឆ្នាំ១៩៨៥ ត្រូវបានធ្វើឡើង បន្ទាប់ពីកងទ័ពយួន បានមកវាយប្រហារ ឆ្នាំ១៩៧៨ និងកាន់កាប់កម្ពុជា ជាចំហ ហើយបានចាត់តាំងអាជ្ញាធរខ្មែរមួយ ហៅថា«សាធារណរដ្ឋប្រជាមានិតកម្ពុជា (ស.ប.ក.)» ឲ្យចុះសន្ធិសញ្ញានយោបាយ និងសន្ធិសញ្ញាទឹកដីថ្មី រវាងយៀកណាម-កម្ពុជា ដែលត្រូវបានអន្តរជាតិ រួមទាំង អ.ស.ប.(UN) ថ្កោលទោស ពីព្រោះវាផ្ទុយនឹងច្បាប់អន្តរជាតិទាំងស្រុង។

២- កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញនៃកម្ពុជា ឆ្នាំ១៩៩៣ ក៏បានឲ្យលុបចោលសន្ធិសញ្ញាទាំងអស់ នៃសម័យយួនកាន់កាប់កម្ពុជានោះ ដែលប៉ះពាល់បូរណភាពទឹកដី នៃប្រទេសកម្ពុជា។

**៣-** អ្នកជំនាញការផែនទីភូមិសាស្រ្ត នៃគណៈកម្មាធិការយើង បានសិក្សាឃើញថា៖ **ក)** និយាមកា ភូមិសាស្រ្តទាំងអស់ ដែលគេបានកំណត់ក្នុងសន្ធិសញ្ញាឆ្នាំ១៩៨៥ នោះ មានលក្ខណៈមិនច្បាស់លាស់ និងមិនអាចប្រើការបាន នៅលើផែនទីភូមិសាស្រ្តណាមួយទេ។ **ខ)** ផែនទី ដែលយួនបានគូសជាបន្ទាប់ សម្រាប់ការកំណត់ខ្សែព្រំដែន និងការបោះបង្គោលព្រំដែន មិនមានទិន្នន័យបច្ចេកទេស សម្រាប់ការកំណត់នៅលើទីដីបានទេ ហើយវាមិនមែនជាផែនទី«បោន» ខ្នាត ១/១០០.០០០ ដូចអ្នក ខ្លះបានអះអាងនោះទេ។ យើងគួររំលឹកទៀតថា ព្រះ

ករុណា នរោត្តម សីហនុ ក៏លោកបានយល់ថា ផែនទីកម្ពុជា ដែលលោក វ៉ា គិម ហុង បានយកមកថ្វាយលោក ទត ជា«**ផែនទីក្លែងក្លាយសុទ្ធសាធ**» ដែរ។

**៤-** សន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥ ដែលជាការបន្ថែមសេចក្តី លើសន្ធិសញ្ញាឆ្នាំ១៩៨៥ ដែលជាសន្ធិសញ្ញា ខុសច្បាប់ **ក៏វាត្រូវជាសន្ធិសញ្ញាខុសច្បាប់ដូចគ្នា**។ ភាពខុសច្បាប់មួយទៀត គឺសន្ធិសញ្ញាឆ្នាំ២០០៥ ត្រូវបាន ទទួលសច្ចាប័នពីសភា និងពីព្រះមហាក្សត្រ ក្រោមការគម្រាមកំហែងយ៉ាងខ្លាំងនៃ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថា នឹងផ្លាស់ប្តូររបបរដ្ឋ ដោយមានការរំលាយ ស្ថាប័នរាជាធិបតេយ្យចោល បើព្រះមហាក្សត្រ មិនព្រមផ្តល់សច្ចាប័ន លើសន្ធិសញ្ញាឆ្នាំ២០០៥ នោះ ដែល ហ៊ុន សែន បានសម្រេច ជាមួយយួនហាណូយ រួចហើយ។

**៥-** នៅថ្ងៃទី១៥ កក្កដា ២០១៥ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរសំបុត្រជាផ្លូវការមួយច្បាប់ ទៅប្រធានា-ធិបតីបារាំង ហ្វ្រង់ស្វ័រ ហូឡង់ (François Hollande) សុំឲ្យបារាំងបញ្ជូនអ្នកជំនាញការផែនទី ជួយដោះស្រាយ ចំណុចទំនាស់ខ្លះ នៃការកំណត់ខ្សែព្រំដែនយៀកណាម-កម្ពុជា។ លោក ហ្វ្រង់ស្វ័រ ហូឡង់ បានឆ្លើយតប វិញថា នឹងព្រមទទួលសំណើនោះ បើភាគីទាំងពីរធ្វើសេចក្តីស្នើទៅ លោកដូចគ្នា។ **ប៉ុន្តែនៅទីបំផុត ហ៊ុន សែន មិនព្រម ឲ្យអ្នកជំនាញការផែនទីបារាំង មកជួយដោះស្រាយ ចំណុចទំនាស់នោះវិញទេ** ដោយពិតជាមិន ចង់ឲ្យបារាំង យកផែនទី«បោន» ខ្នាត ១/១០០.០០០ របស់បារាំង មកធ្វើជាមូលដ្ឋាន នៃការដោះស្រាយនោះ ទេ។

**៦-** ការបោះបង្គោលព្រំដែនថ្មី យៀកណាម-កម្ពុជា បានផ្តើមធ្វើជាសម្ងាត់ នៅបារីត (ខែត្រស្វាយរៀង) នៅថ្ងៃ ២៤/០៤/១៩៨៦។ ការសម្ពោធជាផ្លូវការលើកទី១ នៃបង្គោលព្រំដែនថ្មី បានធ្វើឡើងនៅថ្ងៃ ២៧/០៩/២០០៦ នៅបារីត ដែលពេលនោះ នាយករដ្ឋមន្ត្រីយួន ង្វៀន តន់យុង បានថ្លែងថា ជា«ព្រឹត្តិការណ៍នៃជ័យជំនះជា ប្រវត្តិសាស្ត្រ នៃប្រជាជនយើងទាំងពីរ»។ ទីភ្នាក់ងារព័ត៌មានចិន «ស៊ីនហួ» (XINHUA) ដែលបានទៅទីនោះដែរ បានធ្វើការសង្កេតថា «**តាំងពីឆ្នាំ១៩៧៩ មក ការកំណត់ខ្សែ បន្ទាត់ព្រំដែនថ្មី យៀកណាម-កម្ពុជា មិនដែលបាន ធ្វើឡើងដោយប្រជាជនទាំងពីរ ដឹងឮ និងយល់ព្រមទេ**»។ ការពិតគឺប្រជាពលរដ្ឋខ្មែរ តាំងពីខែត្ររតនគីរី មណ្ឌល គីរី ចុះរហូតមកដល់ ខែត្រតាកែវ កំពត តែងតែបានជំទាស់ និងស្រែកតវ៉ាឥតឈប់ឈរ នឹងការកំណត់បង្គោល ព្រំដែនថ្មី តាមភូមិឃុំរបស់ខ្លួន ជាប់ព្រំដែននោះ ប៉ុន្តែរដ្ឋាភិបាលយួន និង ហ៊ុន សែន ធ្វើមិនដឹងមិនឮទេ បើគេ មិនចាប់អ្នកជំទាស់ និងអ្នកស្រែកតវ៉ាទាំងនោះ ទៅធ្វើទុក្ខទោសទេ។ នេះជាការរំលោភអំណាចជាក់ស្តែង ដោយ គេមិនគោរពតាមគោលការណ៍ និងការប្រព្រឹត្តអន្តរជាតិក្នុងការកំណត់ព្រំដែន ដែលតម្រូវឲ្យមានការយល់ព្រម អំពីអ្នកស្រុក នៅតាមព្រំដែននោះ ជាចាំបាច់។

ជាបញ្ចប់ យើងឃើញច្បាស់ថា យៀកណាមកុម្មុយនីស្ត ដែលអួតអាងខ្លាំងណាស់ ក្នុងជម្លោះទឹកដី ជាមួយចិន ថាខ្លួនជាអ្នកគោរពច្បាប់អន្តរជាតិយ៉ាងហ្មត់ចត់ណាស់ យៀកណាមនេះ មិនបានគោរពច្បាប់អន្តរជាតិអ្វីទាំង អស់ ក្នុងការកំណត់ព្រំដែនទឹកដី ជាមួយកម្ពុជា។ តាំងពីជាង៤០ឆ្នាំមកនេះ យៀកណាម បានចាត់ការរឿង ព្រំដែនទឹកដីហ្នឹង ដូចជាកម្ពុជា ជាដែនអាណានិគមរបស់ខ្លួន ដែលខ្លួនបានវាយប្រហារយកបាន។ **រដ្ឋាភិបាល ហ៊ុន សែន ក៏បានខំលាក់បំបាំង និងភរកូតជានិច្ចជាកាល** អំពីការកំណត់ព្រំដែនទឹកដីហ្នឹង មិនឲ្យពលរដ្ឋខ្មែរ និង មតិអន្តរជាតិ ដឹងឮទេ ពីព្រោះ... វាបានធ្វើឲ្យខាត បង់ច្រើនណាស់ ដល់កម្ពុជា!។

ប្រជាពលរដ្ឋខ្មែរគ្រប់ស្រករ និងនៅគ្រប់ទិសទី មិនអាចទទួលអំណាចអាណានិគមនិយម នៃយៀកណាមនោះ ឡើយ។ ខ្សែព្រំដែន និងបង្គោលព្រំដែនទាំងនោះ នឹងត្រូវទុកជាមោឃៈ និងត្រូវកំណត់ជាថ្មី ស្របតាមច្បាប់ អន្តរជាតិ នៅក្នុងអនាគតកាល ជាចាំបាច់។

ទីក្រុងប៉ារីស ថ្ងៃទី៧ សីហា ២០២០

**ឌី ការ៉េត**